ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខ: ០៤០ ស.ជ.ណ/គ.ជ.អ.ប

ថ្ងៃ១៣.រោច... ខែចេត្រ.... ឆ្នាំជូត.ទោស័ក... ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី...២០....... ខែ..មេសា..... ឆ្នាំ២០២០..

# សូមជម្រាបជូន

## ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាល គ្រប់រាជធានី ខេត្ត

**<u>កម្មវត្ថុ</u>÷** ស្តីពីការបន្តអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម នៅថ្នាក់ក្រុង ស្រុក ខណ្ឌគោលដៅ នៃការផ្តល់សេវា (រដ្ឋបាលឃុំ រដ្ឋបាលសង្កាត់ សាលាបឋមសិក្សា និងការផ្តល់សេវានៅមណ្ឌលសុខភាព) និងផែនការអនុវត្តគណនេយ្យភាពសង្គម ដំណាក់កាលទី២ នៅថ្នាក់រដ្ឋបាលក្រុង រដ្ឋបាលស្រុក និងរដ្ឋបាលខណ្ឌ នៃរាជធានី ខេត្ត។

**<u>យោង</u>÷** -ចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប** លើលិខិតស្នើសុំគោលការណ៍គោរពពិនិត្យ សម្រេច អនុញ្ញាតឱ្យលេខាធិការដ្ឋាន គ.ជ.អ.ប ចុះអនុស្សារណៈយោគយល់ជាមួយអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI360) ដើម្បីអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី២ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០។

-ផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់ គ.ជ.អ.ប.។

-ផែនការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (២០១៩-២០២៣) របស់ គ.ជ.អ.ប និងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ របស់លេខាធិការដ្ឋាន គ.ជ.អ.ប។

-លិខិតលេខ៨៣០ស.ជ.ណ/គ.ជ.អ.ប អំពីការបញ្ចូលផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម(ផ.ស.រ.គ) ទៅក្នុងដំណើរការកសាងកម្មវិធីវិនិយោគប្រចាំឆ្នាំឃុំ សង្កាត់ និងការរៀបចំបង្កើតគណៈកម្មាធិការ (ផ.ស.រ.គ)សម្រាប់ការអនុវត្តការងារគណេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ របស់លេខាធិការដ្ឋាន គ.ជ.អ.ប ។

-សេចក្តីសម្រេចរួមរវាង គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ គ.ជ.អ.ប និងរដ្ឋបាលរាជធានី ខេត្ត ស្តីពីការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

-អនុស្សរណៈយោគយល់រវាងលេខាធិការដ្ឋាន គ.ជ.អ.ប និងអង្គការយែរអន្តរជាតិប្រចាំកម្ពុជា អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) អង្គការទស្សនៈពិភពលោក អង្គការស្តារកម្ពុជា អង្គការសម្ព័ន្ធសុខភាពកុមារ និងសុខភាពបន្តពូជ (រ៉ាឆា) អង្គការអុកស្វាមកម្ពុជា ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមជម្រាបជូន **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា ការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមគឺជាលទ្ធផលរំពឹងទុកមួយ នៃចង្កោមសកម្មភាពទី២ កម្មវិធីជាតិ (១០ឆ្នាំ) សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ របស់រាជរដ្ឋាភិបាល។ ផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមនេះ មានគោលបំណង គឺដើម្បីផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋ ក្នុងការចូលរួមពង្រឹងការចាត់ចែង ការប្រើប្រាស់ថវិកា និងការផ្តល់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិប្រកបដោយគុណភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធភាពតាមរយៈការលើកកម្ពស់នូវភាពងាយទទួល

បានព័ត៌មាននានា និងការចូលរួមពិនិត្យតាមដានលើការបំពេញតួនាទី ភារកិច្ច និងការងារថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គម (ផ.អ.គ.ស) ដំណាក់កាលទី២ (២០១៩-២០២៣) នឹងត្រូវពង្រីកការអនុវត្តគ្របដណ្តប់នៅក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស។ ទន្ទឹមជាមួយនេះការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គម ក្នុងឆ្នាំ ២០២០នេះ បានបន្តពង្រីកការអនុវត្តនៅថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នៃរាជធានី ខេត្ត ដោយអនុវត្តលើពីរផ្នែក គឺ **ផ្នែកផ្គត់ផ្គង់** និងគាំទ្របច្ចេកទេសដល់ **ផ្នែកតម្រូវការ៖**

១).**ផ្នែកផ្គត់ផ្គង់៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ** ការអនុវត្តនៅថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌគោលដៅចំនួន **១៧០**នៃអង្គភាពផ្តល់សេវា(នៅរដ្ឋបាលឃុំ សង្កាត់ចំនួន**១៣៩៩** សាលាបឋមសិក្សាចំនួន**៦១៧៥** និងមណ្ឌលសុខភាពចំនួន**១០៩៧**) ព្រមទាំងការអនុវត្ត I-SAF នៅថ្នាក់រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌចំនួន**០៥** នៃរាជធានី ខេត្តចំនួន០៣) ការអនុវត្តនឹងពង្រីកតំបន់គោលដៅនៅក្នុងឆ្នាំខាងមុខនេះជាបន្តបន្ទាប់ទៀតទូទាំប្រទេស។

**២).ផ្នែកតម្រូវការ៖ អង្គការមិនមែនរដ្ឋាភិបាល** (អង្គការសង្គមស៊ីវិល ជាអង្គការដៃគូអនុវត្ត និងប្រជាពលរដ្ឋ)៖

**ក).អង្គការទស្សនៈពិភពលោក** (World Vision)៖ សហការអនុវត្តដោយអង្គការសង្គមស៊ីវិលចំនួន**១៥** គឺអង្គការសម្ព័ន្ធសុខភាពកុមារ និងសុខភាពបន្តពូជ(RACHA) អង្គការស្តារកម្ពុជា អង្គការសកម្មភាពព្រះពុទ្ធដើម្បីអភិវឌ្ឍន៍សង្គម អង្គការពន្លឺកុមារ អង្គការសកម្មភាពដើម្បីអភិវឌ្ឍន៍ អង្គការសុវណ្ណភូមិ អង្គការអ្នកអភិវឌ្ឍន៍សហគមន៍ អង្គការវឌ្ឍនភាព អង្គការភាពជាដៃគូសង្គមស៊ីវិលកម្ពុជា អង្គការជំនួយអភិវឌ្ឍន៍ និងសន្តិភាព ក្រុមប្រឹក្សាយុវជនកម្ពុជា អង្គការកំណើតបំផ្លាស់បំប្រែសហគមន៍ អង្គការខ្មែរអភិវឌ្ឍន៍ជនពិការ និងអ្នកក្រីក្រ អង្គការសម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម អង្គការមណ្ឌលអភិវឌ្ឍន៍សហគមន៍ អនុវត្តនៅរដ្ឋបាលឃុំចំនួន**៩៤៩** សង្កាត់ចំនួន **២៣** នៃការផ្តល់សេវា (រដ្ឋបាលឃុំ រដ្ឋបាលសង្កាត់ សាលាបឋមសិក្សា និងការផ្តល់សេវានៅមណ្ឌសុខភាព) ក្នុងក្រុងចំនួន**០៦** ស្រុកចំនួន**៤៩** នៃខេត្តចំនួន**១៥** គឺខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តព្រះវិហារ ខេត្តសៀមរាប ខេត្តពោធិ៍សាត់ ខេត្តកំពង់ចាម ខេត្តតាកែវ ខេត្តកណ្តាល ខេត្តកែប ខេត្តព្រះសីហនុ និងអនុវត្តសាកល្បងការផ្តល់សេវានៅរដ្ឋបាលថ្នាក់ខណ្ឌចំនួន០២ ថ្នាក់រដ្ឋបាលសង្កាត់ចំនួន០៤ គោលដៅអង្គភាពផ្តល់សេវានៃការអនុវត្តនេះនឹងពង្រីកជាបន្តបន្ទាប់ទៀតនៅក្នុងឆ្នាំខាងមុខ។

**ខ). អង្គការឃែរអន្តរជាតិប្រចាំកម្ពុជា** (CARE)៖ សហការអនុវត្តដោយអង្គការសង្គមស៊ីវិលចំនួន**១៤** គឺអង្គការថែរក្សាភាសាជនជាតិដើមភាគតិច អង្គការសង្គ្រោះជនងាយរងគ្រោះកម្ពុជា អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ អង្គការក្រុមការងារ ដើម្បីដោះស្រាយទំនាស់ អង្គការសមាគមពាណិជ្ជកម្មឌីជីថលកម្ពុជា អង្គការសម្ព័ន្ធសុខភាព និងអភិវឌ្ឍន៍ អង្គការអភិវឌ្ឍន៍សុខភាពគ្រួសារ អង្គការសកម្មភាពដើម្បីអភិវឌ្ឍន៍សុខភាព អង្គការអ្នកអភិវឌ្ឍន៍សហគមន៍ អង្គការមណ្ឌលអភិវឌ្ឍន៍សហគមន៍ អង្គការសកម្មភាពដើម្បីសុខុមាលភាពស្ត្រីកម្ពុជា ក្រុមប្រឹក្សាយុវជនកម្ពុជា អង្គការអភិវឌ្ឍន៍ជនពិការ និងអ្នកក្រីក្រ អង្គការសមាគមខ្មែរដើម្បីអភិវឌ្ឍន៍តាមជនបទ ដែលអនុវត្តនៅរដ្ឋបាលឃុំចំនួន**១០២** សង្កាត់ចំនួន**២០** នៃការផ្តល់សេវា (រដ្ឋបាលឃុំ រដ្ឋបាលសង្កាត់ សាលាបឋមសិក្សា និងការផ្តល់សេវានៅមណ្ឌសុខភាព) ក្នុងក្រុងចំនួន**០៥** ស្រុកចំនួន**២៨** នៃខេត្តចំនួន**០៥** គឺខេត្តកោះកុង ខេត្តមណ្ឌលគីរី ខេត្តរតនគិរី ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង។

**គ).អង្គការសុខភាពគ្រួសារអន្តរជាតិ**(FHI360)៖ សហការអនុវត្តដោយអង្គការសង្គមស៊ីវិលចំនួន**០៦** គឺអង្គការសម្ព័ន្ធ

សុខភាពកុមារ និងសុខភាពបន្តពូជ(RACHA) អង្គការស្តារកម្ពុជា វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ(API) អង្គការភ្នំស្រីដើម្បីអភិវឌ្ឍន៍ នៅរដ្ឋបាលសង្កាត់ចំនួន៥១ នៃការផ្តល់សេវា (រដ្ឋបាលសង្កាត់ សាលាបឋមសិក្សា និងការផ្តល់សេវានៅមណ្ឌលសុខភាព) ក្នុងក្រុងចំនួន០៧ នៃខេត្តចំនួន០៦ គឺ ក្រុងសិរីសោភ័ណ្ឌ និងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ក្រុងកំពត ខេត្តកំពត ក្រុងសៀមរាប ខេត្តសៀមរាប និងក្រុងតាខ្មៅ ខេត្តកណ្តាល។

**ឃ). អនុវត្តដោយអង្គការសម្ព័ន្ធសុខភាពកុមារ និងសុខភាពបន្តពូជ(RACHA)៖** អនុវត្តនៅរដ្ឋបាលឃុំចំនួន៨៣ នៃការផ្តល់សេវា (រដ្ឋបាលឃុំ សាលាបឋមសិក្សា និងការផ្តល់សេវានៅមណ្ឌលសុខភាព) ក្នុងស្រុកចំនួន១០ នៃខេត្តចំនួន០៦ គឺខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ស្ពឺ ខេត្តពោធិ៍សាត់ ខេត្តសៀមរាប និងខេត្តប៉ៃលិន។

**ង). អនុវត្តដោយអង្គការស្តារកម្ពុជា (STAR Kampuchea)៖** នៅរដ្ឋបាលឃុំចំនួន២២ នៃការផ្តល់សេវា (រដ្ឋបាលឃុំ សាលាបឋមសិក្សា និងការផ្តល់សេវានៅមណ្ឌលសុខភាព) ក្នុងស្រុកគោលដៅចំនួន០២គឺស្រុកចន្ទ្រា និងស្រុករមាសហែក ខេត្តស្វាយរៀង។

**ច). អង្គការអុកស្វាមកម្ពុជា (OXFAM)៖** សហការអនុវត្តដោយវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) នៅក្នុងរដ្ឋបាលសង្កាត់ចំនួន០៣ គឺសង្កាត់ទឹកថ្លា សង្កាត់គោកឃ្លាង និងសង្កាត់ឃ្មួញក្នុងរដ្ឋបាលខណ្ឌសែនសុខ នៃរាជធានីភ្នំពេញ។

ការអនុវត្តផ្នែកគម្រូវការនឹងពង្រីកតំបន់គោលដៅនៅក្នុងឆ្នាំខាងមុខនេះជាបន្តបន្ទាប់ទៀតទូទាំងប្រទេស។

សូមជូនភ្ជាប់មកជាមួយនូវអនុស្សរណៈយោគយល់ តំបន់គោលដៅ យន្តការគាំទ្រ និងនីតិវិធីអនុវត្ត ឧបសម្ព័ន្ធផ្សេងៗ និងឯកសារពាក់ព័ន្ធមួយចំនួនទៀត។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត** មេត្តាបន្តផ្តល់កិច្ចសហការ គាំទ្រដំណើរការអនុវត្ត និងចាត់តាំងបង្កើតក្រុមការងារ ផ.អ.គ.ស មានមន្ត្រីបង្គោលទទួលគណនេយ្យភាពសង្គមថ្នាក់រាជធានី ខេត្ត និងក្រុមការងារ ផ.អ.គ.ស មានមន្ត្រីបង្គោលទទួលគណនេយ្យភាពសង្គមថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីសម្របសម្រួលគាំទ្រដំណើរការអនុវត្តគម្រោងគណនេយ្យភាពសង្គម ដំណាក់កាលទី២ ឱ្យទទួលបានលទ្ធផលល្អប្រសើរ តាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវការគោរពគោរពរាប់អានដ៏ស្មោះអំពីខ្ញុំ។៕

**រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជា**
**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.** ០៥

ងិន់ ជំរើន

*ចម្លងជូន:*
- គណៈកម្មាធិការជាតិ គ.ជ.អ.ប
- គណៈកម្មាធិការ គ.គ.អ.ស
- ក្រសួងមហាផ្ទៃ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធ
- ធនាគារពិភពលោក ប្រចាំកម្ពុជា «ដើម្បីជូនជ្រាប»
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់
- អង្គការទស្សនៈពិភពលោក អង្គការឃែរ អង្គការវ៉ាដា
- អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360)
- អង្គការស្តារកម្ពុជា និងអង្គការអុកស្វាមកម្ពុជា និង
- អង្គការដៃគូអនុវត្ត I-SAF ផ្សេងៗទៀត «ដើម្បីសហការអនុវត្ត»
- ឯកសារ កាលប្បវត្តិ